

ពាណិជ្ជកម្មសេរី

# កសិកម្មសរីរាង្គកម្ពុជា

# ORGANIC FARMING IN CAMBODIA





## ១. អ្វីទៅជាពាណិជ្ជកម្មសេរី?

- គឺជាចលនាមួយដែលបង្កើតឱ្យមានលក្ខខណ្ឌប្រកបដោយភាពសុច្ចរិត និងយុត្តិធម៌ នៅក្នុងផលិតកម្ម និងពាណិជ្ជកម្មទំនិញ ។

- ធ្វើឡើងដោយបង្កើតស្តង់ដារ និងផ្តល់គោលការណ៍ណែនាំសមស្របទាក់ទងនឹងការផ្តល់ប្រាក់ខែ និងលក្ខខណ្ឌការងាររបស់កម្មករ និងផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថាន នៃការងារផលិតកម្ម និងពាណិជ្ជកម្ម ។





- ផ្តោតលើបញ្ហាអសមភាពនៅក្នុងពិភពលោក ដោយមានយុទ្ធសាស្ត្រ តំរង់ទិសទៅលើការអភិវឌ្ឍនប្រកបដោយនិរន្តរភាព សំរាប់អ្នកផលិតដែលក្រីក្រ ។
- អង្គការស្លាកសញ្ញាពាណិជ្ជកម្មសេរីអន្តរជាតិ (FLO) គឺជា ស្ថាប័នអន្តរជាតិមួយដែលមានប្រទេសធំៗចំនួន ២0 ជាសមាជិកនៅលើពិភពលោកជាអ្នកចេញលិខិតបញ្ជាក់
- គោលបំណងសំខាន់គឺ គាំទ្រអ្នកផលិត ដើម្បីលើកកំពស់ជីវភាពរស់នៅដោយធានានូវភាពយុត្តិធមិ ផ្នែកផលិតកម្ម និងពាណិជ្ជកម្ម ។



## ២. ការឯកភាពជាគោលការណ៍

- ការធ្វើពាណិជ្ជកម្មសេរី ត្រូវផ្តល់គំនិតផ្តួចផ្តើមដើម្បីរៀបចំអោយមាន ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ដែលបង្កើតឱ្យមានយុត្តិធមិ ឬសមធមិ ក្នុងការប្រើ កំលាំងពលកម្ម និងមានបរិយាកាសការងារប្រកបដោយសុវត្ថិភាព ។

- ការធ្វើពាណិជ្ជកម្មសេរី ត្រូវមាននិតិវិធីប្រកបដោយភាពយុត្តិធមិ ផ្អែកតម្លៃទំនិញ ហើយកំរិតប្រាក់ខែកំរិតប្រាក់ខែរបស់កម្មករ ត្រូវមាន លក្ខណះសមស្របតាមទំហំការងារ និងប្រាក់ចំណូល





- ផលិតកម្មទំនិញរបស់ពាណិជ្ជកម្មសេរី ត្រូវធ្វើឡើងតាមមធ្យោបាយ និរន្តរភាព ដោយផ្អែកលើគោលការណ៍ប្រព័ន្ធអេកូឡូស៊ី ដែលគាំពារ សុខភាពពីភពផែនដី សំរាប់មនុស្សគ្រប់រូប

- លក្ខខណ្ឌជីវភាពរស់នៅរបស់ប្រជាជន ត្រូវបានលើកកំពស់តាមរយៈការប្រើប្រាស់ ផលិតផលនៃការធ្វើពាណិជ្ជកម្មសេរី របស់អតិភិជន